# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៧៣៦ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាលអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៤ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម
- តាមសំណើរបស់ធនាគារជាតិនៃកម្ពុជា

## ស ម្រេ ច

**មាត្រា១.~**

ត្រូវបានតែងតាំងសមាសភាពសមាជិកក្រុមប្រឹក្សាភិបាល សម្រាប់ដឹកនាំអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា អាណត្តិទី២ ចំនួន ៥រូប ដូចមានរាយនាមខាងក្រោម ៖

១- **ឯកឧត្តម ជា ចាន់តូ** តំណាងធនាគារជាតិនៃកម្ពុជា ប្រធានក្រុមប្រឹក្សាភិបាល បន្ថែមលើមុខងារបច្ចុប្បន្ន

២- **ឯកឧត្តម ប៉ែន ពេជ្រសាលី** តំណាងក្រសួងយុត្តិធម៌ សមាជិកក្រុមប្រឹក្សាភិបាល បន្ថែមលើមុខងារបច្ចុប្បន្ន

៣- **ឯកឧត្តម គឹម រ័ត្នវិសិដ្ឋ** តំណាងទីស្តីការគណៈរដ្ឋមន្ត្រី សមាជិកក្រុមប្រឹក្សាភិបាល បន្ថែមលើមុខងារបច្ចុប្បន្ន

៤- **លោកឧត្តមសេនីយ៍ទោ កែវ វណ្ណថន** តំណាងក្រសួងមហាផ្ទៃ សមាជិកក្រុមប្រឹក្សាភិបាល បន្ថែមលើមុខងារបច្ចុប្បន្ន

៥- **លោក ម៉ី វ៉ាន់** តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិកក្រុមប្រឹក្សាភិបាល បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា២.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ២០១០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**__កន្លែងទទួល:__**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
  ដើម្បីជូនជ្រាប
- ដូចក្នុងមាត្រា៣ «ដើម្បីអនុវត្ត»
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ